00643046

E35/1

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: សាធារណៈ / Public

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញា**
**សុំការបំភ្លឺអំពីនីតិវិធីសម្រាប់ការឆ្លើយតបទៅនឹងអញ្ញត្រកម្មបឋម**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម ធូ មណី

សហមេធាវីនាំមុខតំណាង
ដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
ជនជាប់ចោទ:
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 09 / 02 / 2011
ម៉ោង (Time/Heure): 15:55
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

E35/1

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសជ*

លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក ស សូវាន
លោក Jacques VERGÈS
លោក Phillipe GRECIANO

00643048

E35/1

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ*

**សំណើ**

១. នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១ សហព្រះរាជអាជ្ញា បានទទួលការជូនដំណឹងអំពីអញ្ញត្រកម្មបឋម របស់ នួន ជា ទាក់ទងនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E36) ។ ដូច បានបញ្ជាក់បំភ្លឺនៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១ (ឯកសារលេខ E35) ជនជាប់ចោទមានពេលរហូតដល់ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ដើម្បីដាក់ អញ្ញត្រកម្មបឋម ដោយអនុលោមទៅតាមវិធាន៨៩ នៃវិធានផ្ទៃក្នុង ។ អង្គជំនុំជម្រះសាលាដំបូង បានចង្អុលបង្ហាញថា ក្រោយពេលសំអាងហេតុពេញលេញ ត្រូវបានផ្តល់ដោយអង្គបុរេជំនុំជម្រះ សម្រាប់ធ្វើការសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាដំណោះស្រាយ អង្គជំនុំជម្រះសាលាដំបូង នឹងពិចារណាថាតើអនុញ្ញាតឱ្យមាន "សេចក្តីសន្និដ្ឋាន/សារណាបន្ថែមណាខ្លះ" ដែរឬអត់ (ឯកសារ លេខ E35) ។

២. ទាក់ទងនឹងអញ្ញត្រកម្មបឋមបែបនេះ វិធាន៨៩.៣ នៃវិធានផ្ទៃក្នុង ចែងថា អង្គជំនុំជម្រះសាលា ដំបូង"ត្រូវសម្រេចជាបន្ទាន់អំពីអញ្ញត្រកម្ម តាមសេចក្តីសម្រេចមួយដែលមានសំអាងហេតុ ឬ នៅពេលដំណាលគ្នា នឹងសាលក្រមលើអង្គសេចក្តី" ។ វិធាន៨៩.២ នៃវិធានផ្ទៃក្នុង ចែងថា អង្គជំនុំជម្រះសាលាដំបូង "ត្រូវផ្តល់ឱ្យភាគីម្ខាងទៀតនូវឱកាសឆ្លើយតបទៅនឹងអញ្ញត្រកម្ម" ។ វិធាន ៨០ស្ទួន.៣ នៃវិធានផ្ទៃក្នុងចែងថា នៅក្នុងពេលសវនាការបឋម អង្គជំនុំជម្រះសាលាដំបូង "ត្រូវពិចារណាបញ្ហាទាក់ទងទៅនឹងវិធាន៨៩" ។

៣. ដោយហេតុថា អនុស្សរណៈ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១ របស់អង្គជំនុំជម្រះ មិនបានពិភាក្សា សំដៅទៅដល់ចម្លើយតបផ្សេងៗ ទៅនឹងអញ្ញត្រកម្មបឋមនានា នោះសហព្រះរាជអាជ្ញាស្នើអោយ មានការបញ្ជាក់ឱ្យបានច្បាស់លាស់ពីសំណាក់អង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាម វិធាន៨៩.២ នៃវិធានផ្ទៃក្នុងស្តីពីនីតិវិធី និងពេលវេលាសម្រាប់ចម្លើយតបនានា ទៅនឹងអញ្ញត្រកម្ម បឋមទាំងនោះ ។ ដោយមានមូលដ្ឋាននៅលើបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ របស់ពួកគេ វាត្រូវបានគេប្រមើលមើលបានថា ជនជាប់ចោទទាំងអស់ ឬមួយចំនួន អាចនឹងធ្វើ អញ្ញត្រកម្មលើបញ្ហាយុត្តាធិការដូចៗគ្នា ។ ហេតុដូច្នេះ ដើម្បីចៀសវាងការធ្វើសារណាដែលមាន លក្ខណៈច្រំដែល នោះសហព្រះរាជអាជ្ញា សូមស្នើអនុញ្ញាតដាក់ជាចម្លើយតបបង្រួមចូលគ្នាមួយ ដែលមានជនជាប់ចោទច្រើននាក់ ដែលលើកឡើងនូវអញ្ញត្រកម្មលើបញ្ហាយុត្តាធិការដូចៗគ្នា ។ សហព្រះរាជអាជ្ញា ក៏សូមធ្វើការស្វែងរកនូវការបញ្ជាក់ឱ្យបានច្បាស់លាស់ផងដែរ ថាតើនៅពេល ណាដែលអង្គជំនុំជម្រះសាលាដំបូង មានបំណងឱ្យដាក់សារណាឆ្លើយតបទាំងនោះ និងសូមស្នើ ដាក់ចម្លើយតបបែបដូច្នោះ កុំឱ្យហួសថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | | |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | |